គ.ជ.ប

# ព្រឹត្តិបត្រ

## គោលនយោបាយរបស់គណបក្សនយោបាយ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ចេញផ្សាយថ្ងៃទី៩ ខែកុម្ភៈ ឆ្នាំ២០២៤ លេខ ២

# ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា

## នីតិកាលទី៥ ឆ្នាំ២០២៤

ថ្ងៃបោះឆ្នោត ៖ នៅថ្ងៃអាទិត្យ ទី២៥ ខែកុម្ភៈ ឆ្នាំ២០២៤

ទីស្តីការ គ.ជ.ប វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរសព្ទ (Tel) : (+855) 23 235 271

អ៊ីម៉ែល(Email): info@nec.gov.kh

Website: www.nec.gov.kh, voterlist.nec.gov.kh

Facebook/Youtube: National Election Committee

APP: NEC KH, CamNEC News

# មាតិកា

ទំព័រ


• គណបក្សប្រជាជនកម្ពុជា ........................................ ១-៣

• គណបក្សហ៊្វុនស៊ិនប៉ិច ........................................ ៤-៦

• គណបក្ស កម្លាំងជាតិ ........................................ ៧-៩

• គណបក្ស ឆន្ទៈខ្មែរ ........................................ ១០-១២



# គោលការណ៍សំខាន់ៗ
# នៃកម្មវិធីនយោបាយរបស់គណបក្សប្រជាជនកម្ពុជា
# សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាល ទី៥

## គោលការណ៍ជាមូលដ្ឋានសម្រាប់ការអភិវឌ្ឍ ឃុំ សង្កាត់

**១**- លើកកម្ពស់ការគោរពសិទ្ធិធ្វើជាម្ចាស់របស់ប្រជាពលរដ្ឋ ធ្វើឱ្យកាន់តែប្រសើរឡើងនូវឥរិយាបថរបស់មន្ត្រីរាជការ និងអាជ្ញាធរមានសមត្ថកិច្ចក្នុងការបម្រើប្រជាពលរដ្ឋ និងពង្រឹងស្ថាប័នរដ្ឋបាលថ្នាក់ក្រោមជាតិឱ្យកាន់តែមានសមត្ថភាពក្នុងការអភិវឌ្ឍមូលដ្ឋាន ដោយឈរលើគោលការណ៍គន្លឹះនៃអភិបាលកិច្ចល្អ គឺភាពជាតំណាង ការចូលរួមរបស់ប្រជាពលរដ្ឋ ការឆ្លើយតប ប្រសិទ្ធភាព សុចរិតភាព តម្លាភាព គណនេយ្យភាព នីតិរដ្ឋ បរិយាបន្ន និងសមធម៌សង្គម។

**២**- ក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវបានផ្តល់ស្វ័យភាព សិទ្ធិអំណាចក្នុងការដាក់ចេញគោលនយោបាយសម្រាប់ការអភិវឌ្ឍឃុំ សង្កាត់របស់ខ្លួន និងការធ្វើសេចក្តីសម្រេចចិត្តដោយឆន្ទានុសិទ្ធិក្នុងការប្រើប្រាស់ថវិកាការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានដែលបម្រើឱ្យផលប្រយោជន៍របស់ប្រជាពលរដ្ឋស្របតាមច្បាប់ និងលិខិតបទដ្ឋានជាធរមាន។

**៣**- ក្រុមប្រឹក្សាឃុំ សង្កាត់ មានមុខងារ និងការទទួលខុសត្រូវច្បាស់លាស់លើការដឹកនាំ គ្រប់គ្រងចាត់ចែងការងាររដ្ឋបាល សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ធនធានហិរញ្ញវត្ថុ ទ្រព្យសម្បត្តិ បុគ្គលិក និងការផ្តល់សេវាសាធារណៈចាំបាច់ និងជាមូលដ្ឋាននានា ព្រមទាំងការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋានក្នុងដែនសមត្ថកិច្ចរបស់ខ្លួនស្របតាមការកំណត់នៃច្បាប់។

**៤**- បង្កើនល្បឿនការផ្ទេរមុខងារ ភ្ជាប់ជាមួយធនធានមនុស្ស ធនធានហិរញ្ញវត្ថុ និងសិទ្ធិអំណាចពីថ្នាក់ជាតិទៅថ្នាក់ក្រោមជាតិឱ្យបានកាន់តែច្រើន និងទាន់ពេលវេលា ដើម្បីលើកកម្ពស់គុណភាព ប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍលើគ្រប់វិស័យនៅមូលដ្ឋាន៖

– បង្កើនការផ្ទេរធនធានហិរញ្ញវត្ថុពីថវិការដ្ឋបាលថ្នាក់ជាតិដល់មូលនិធិឃុំ សង្កាត់ តាមរយៈកំណើនចំណូលចរន្តថវិកាជាតិ និងបង្កើនអត្រាវិភាជន៍ប្រចាំឆ្នាំនៃមូលនិធិឃុំ សង្កាត់ ពី ៣,៤% នៅឆ្នាំ ២០២៣ ដល់ ៣,៥% ចាប់ពីឆ្នាំ ២០២៤, បន្តការផ្ទេរធនធានបន្ថែម ១% ជូនរដ្ឋបាលឃុំ សង្កាត់ សម្រាប់ចំណាយអភិវឌ្ឍន៍មូលដ្ឋាន និងបង្កើនការចែករំលែកចំណូលសារពើពន្ធរបស់រដ្ឋបាលរាជធានី ខេត្ត ពី ៥,៥% នៅឆ្នាំ ២០២៣ ដល់ ៦% ជូនរដ្ឋបាលឃុំ សង្កាត់ ចាប់ពីឆ្នាំ ២០២៤ តទៅ ដើម្បីឱ្យឃុំ សង្កាត់កាន់តែមានលទ្ធភាពក្នុងការផ្តល់

សេវា និងអភិវឌ្ឍមូលដ្ឋានសិក្សាលទ្ធភាពចែករំលែកប្រភពចំណូលមិនមែនសារពើពន្ធ ពីថ្នាក់ជាតិជូនរដ្ឋបាលឃុំ សង្កាត់

– បង្កើតឱ្យមានយន្តការប្រកួតប្រជែងដោយផ្អែកលើសមិទ្ធកម្ម នៅរដ្ឋបាលឃុំ សង្កាត់ ដើម្បីពង្រឹងសមត្ថភាពនៃការគ្រប់គ្រងធនធានហិរញ្ញវត្ថុ និងដើម្បីទទួលបានធនធានហិរញ្ញវត្ថុបន្ថែមសម្រាប់ការអភិវឌ្ឍមូលដ្ឋាន។

**៥**- ឃុំ សង្កាត់ មានសន្តិសុខ របៀបរៀបរយ សណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គមកាន់តែល្អប្រសើរ តាមរយៈការអនុវត្តគោលនយោបាយភូមិ ឃុំ សង្កាត់ មានសុវត្ថិភាពឱ្យកាន់តែមានប្រសិទ្ធភាព ជាពិសេសការលុបបំបាត់គ្រឿងញៀន ល្បែងស៊ីសង ចោរកម្ម និងសកម្មភាពក្មេងទំនើង។

**៦**- យកចិត្តទុកដាក់លើកកម្ពស់សមត្ថភាពរដ្ឋបាលឃុំ សង្កាត់ បង្កើនប្រាក់ឧបត្ថម្ភប្រចាំខែ គិតគូរអំពីរបបសន្តិសុខសង្គម និងផលប្រយោជន៍ផ្សេងៗទៀតជូនក្រុមប្រឹក្សាឃុំ សង្កាត់ និងភូមិ ខិតខំកៀរគរជំនួយពីដៃគូអភិវឌ្ឍន៍ និងមជ្ឈដ្ឋាននានាទាំងនៅក្នុង និងក្រៅប្រទេសដើម្បីអភិវឌ្ឍឃុំ សង្កាត់។

**៧**- ផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋប្រកបដោយគុណភាព តម្លាភាព គណនេយ្យភាព និងការជឿទុកចិត្ត ៖

– ប្រជាពលរដ្ឋទទួលបានសេវារដ្ឋបាលប្រកបដោយភាពងាយស្រួល សាមញ្ញ និងឆាប់រហ័ស តាមរយៈការរៀបចំយន្តការច្រកចេញចូលតែមួយ។ ការចុះបញ្ជីកំណើត បញ្ជីអាពាហ៍ពិពាហ៍ បញ្ជីមរណភាព ការផ្តល់សៀវភៅស្នាក់នៅ សៀវភៅគ្រួសារ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ ត្រូវបានផ្តល់ជូនដោយឥតគិតថ្លៃ

– កុមារ និងយុវជនបានរៀនសូត្រគ្រប់គ្នាប្រកបដោយសមធម៌ និងគុណភាព ដោយមានការយកចិត្តទុកដាក់ខ្ពស់ពីរដ្ឋ ការបង្កឱកាសគ្រប់យ៉ាងឱ្យកុមារ និងយុវជនបានចូលរៀន និងការបង្កើតសាលារៀនឱ្យទៅជិតលំនៅឋានរបស់ប្រជាជន

– ជំរុញការបណ្តុះបណ្តាលអក្ខរកម្មបច្ចេកវិទ្យាឌីជីថលដល់លោកគ្រូ អ្នកគ្រូ មន្ត្រីរាជការ និងប្រជាពលរដ្ឋនៅតាមមូលដ្ឋានឃុំ សង្កាត់

– ពង្រីកការថែទាំសុខភាពឆ្ពោះទៅការគ្របដណ្តប់សុខភាពជាសាកល ដោយចាប់ផ្តើមពីការពង្រីកមូលនិធិសមធម៌សុខាភិបាលដល់គ្រួសារងាយរងហានិភ័យ និងពង្រីករបបថែទាំសុខភាពរបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.)

– អភិវឌ្ឍគ្រប់ឃុំ សង្កាត់ ឱ្យមានផ្លូវគមនាគមន៍កាន់តែល្អ តាមរយៈការជួសជុលថែទាំផ្លូវជាប្រចាំ ការស្ថាបនាផ្លូវថ្មីៗថែមទៀត និងការលើកកម្ពស់ផ្លូវពីផ្លូវដីទៅជាផ្លូវក្រាលក្រួសក្រហម ក្រាលកៅស៊ូ ឬផ្លូវបេតុង, មានអគ្គិសនី និងទឹកស្អាតប្រើប្រាស់គ្រប់គ្រាន់, មានប្រព័ន្ធធារាសាស្ត្រកាន់តែប្រសើរឡើង និងមានសេវាទូរគមនាគមន៍ប្រកបដោយគុណភាព

– មិនយកពន្ធលើដីកសិកម្មជាលក្ខណៈគ្រួសារ ជួយកសិករក្នុងការពង្រីកផលិតកម្ម និងការរកទីផ្សារលក់កសិកផលដោយថ្លៃសមរម្យ, បែងចែកដី និងផ្តល់កម្មសិទ្ធិដីជូនគ្រួសារក្រីក្រគ្មានដីដែលបានអនុវត្តតាមលក្ខខណ្ឌសម្បទានដីសង្គមកិច្ច, ទប់ស្កាត់ការទន្ទ្រានកាន់កាប់ដីគ្រប់ប្រភេទរបស់រដ្ឋដោយខុសច្បាប់, បន្តធ្វើប្រទានកម្មដីជូនប្រជាជនរស់នៅ និងអាស្រ័យផលលើទីតាំងដីរដ្ឋតាមគោលការណ៍ដែលបានកំណត់, ជំរុញការដោះស្រាយបញ្ចប់ជម្លោះដីធ្លីក្នុងមូលដ្ឋាន និងបង្កើនល្បឿនការចុះបញ្ជីដីធ្លី និងផ្តល់កម្មសិទ្ធិជូនប្រជាជន

– អនុវត្តគោលការណ៍លុបការបង់ភាសុី និងការបង់ថ្លៃផ្សេងៗទៀត ចំពោះការលក់ដូរតូចតាចរបស់ប្រជាពលរដ្ឋតាមកញ្ច្រែង កញ្ជើ ល្អី នៅតាមទីផ្សារនានានៅទូទាំងប្រទេស, អាជីវករលក់ដូរតាមផ្សាររដ្ឋ និងទីតាំងផ្សាររដ្ឋមានសិទ្ធិកាន់កាប់ ប្រើប្រាស់ និងអាស្រ័យផលលើតូប រាន ស្តង់លក់ដូរ និងមានសិទ្ធិផ្ទេរសិទ្ធិទាំងនេះឱ្យកូនចៅ ឬអ្នកដទៃបាន

– ពង្រឹង និងបង្កើនប្រសិទ្ធភាពក្នុងការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការដោយសន្តិវិធី។

**៨-** ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន និងលើកស្ទួយជីវភាពប្រជាជន តាមរយៈការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ, ការបង្កើនការងារ និងមុខរបរ, ការពង្រីកទីផ្សារសម្រាប់ផលិតផលកសិកម្ម និងសិប្បកម្ម, ការផ្តល់ប្រាក់កម្ចីមានអត្រាការប្រាក់ទាបសមរម្យសម្រាប់បង្កើត និងពង្រីកមុខរបរ, ការពង្រឹងយន្តការនៃការរក្សាស្ថិរភាពថ្លៃម្ហូបអាហារ និងកាត់បន្ថយថ្លៃទឹក និងថ្លៃអគ្គិសនីសម្រាប់ប្រជាជនទូទៅ, ការបញ្ជូនមន្ត្រីបច្ចេកទេសកសិកម្មដល់គ្រប់ឃុំនៅទីជនបទដើម្បីជំរុញការលើកកម្ពស់ផលិតភាពកសិកម្ម និងជួយដល់គ្រួសារកសិករក្នុងការលើកស្ទួយផលិតផលកសិកម្មរបស់ខ្លួន, ការរៀបចំសមាគមកសិករនៅតាមទីជនបទដើម្បីរក្សានូវកម្លាំងរបស់កសិករក្នុងការផលិតក៏ដូចការតថ្លៃជាមួយនឹងអ្នកទទួលទិញ។

**៩-** ជំរុញការអនុវត្តកម្មវិធីជាតិជំនួយសង្គមដោយផ្តល់ការគាំពារដល់គ្រួសារក្រីក្រ ក្រុមជនងាយរងគ្រោះក្នុងគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ក្នុងគ្រាមានវិបត្តិ និងគ្រោះអាសន្ននានា ដើម្បីជួយទ្រទ្រង់ជីវភាព និងផ្តល់ការគាំពារឱ្យបានទាន់ពេល និងមានប្រសិទ្ធភាព ទៅតាមតំបន់ភូមិសាស្ត្រ និងស្ថានភាពជាក់ស្តែងនៃវិបត្តិ ឬគ្រោះអាសន្ន, បន្តអនុវត្តកម្មវិធីឧបត្ថម្ភស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម២ឆ្នាំ, បន្តលើកកម្ពស់ការការពារសិទ្ធិ និងប្រយោជន៍របស់កម្មករ-និយោជិតទាំងក្នុងប្រព័ន្ធ និងនៅក្រៅប្រព័ន្ធ។

**១០-** កសាងឃុំ សង្កាត់ នៅជាប់ព្រំដែនជាមួយប្រទេសជិតខាង ជាឃុំ សង្កាត់ប្រកបដោយសន្តិភាព និងការអភិវឌ្ឍ ប្រជាជនរស់នៅទាំងសងខាងព្រំដែនមានចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការគ្នាល្អប្រសើរ។

ខាងលើនេះ គឺជាគោលការណ៍សំខាន់ៗនៃកម្មវិធីនយោបាយរបស់**គណបក្សប្រជាជនកម្ពុជា**សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៥។ គណបក្សសូមអំពាវនាវដល់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងតំណែងនៅតាមភូមិភាគទាំង៨ និងតំណាងរាស្ត្រក្នុងតំណែង សូមគាំទ្រនូវគោលការណ៍ទាំងនេះ និងសូមអញ្ជើញទៅបោះឆ្នោតគាំទ្រ **គណបក្សប្រជាជនកម្ពុជា** ក្នុងការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានីតិកាលទី៥ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃអាទិត្យ ១រោច ខែមាឃ ឆ្នាំថោះ បញ្ចស័ក ពុទ្ធសករាជ ២៥៦៧ ត្រូវនឹងថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ២០២៤ ខាងមុខនេះ។

| | | | |
|---|---|---|---|
| ១ | | ✓ | **គណបក្សប្រជាជនកម្ពុជា**<br>**ប្រ.ជ** |

**បោះឆ្នោតជូនគណបក្សប្រជាជនកម្ពុជា**

**ដើម្បីសន្តិភាព ប្រជាធិបតេយ្យ និងការអភិវឌ្ឍ!**

៣

# គណបក្សហ៊្វុនស៊ិនប៉ិច នឹងទទួលបានការគាំទ្រពីអ្នកបោះឆ្នោត ព្រឹទ្ធសភា នីតិកាលទី៥ នេះ

គណបក្សហ៊្វុនស៊ិនប៉ិច គឺជាគណបក្សនយោបាយ ដែលមានមូលដ្ឋានគ្រឹះរឹងមាំ និង បានដើរតួយ៉ាងសំខាន់ ទាំងលើឆាកជាតិ អន្តរជាតិ ក្នុងការតស៊ូរំដោះប្រទេស ឱ្យមាន សន្តិភាព សេរីភាព និង បង្រួបបង្រួមខ្មែរគ្រប់និន្នាការនយោបាយ កសាង អភិវឌ្ឍន៍ប្រទេស សាជាថ្មីឡើងវិញ ជាពិសេសចាប់អំពីដំណាក់កាលដែល គណបក្សហ៊្វុនស៊ិនប៉ិច ឈ្នះឆ្នោត ឆ្នាំ១៩៩៣ ដែលទាំងនេះ គឺជាស្នាដៃជាប្រវត្តិសាស្ត្រមិនអាចបំភ្លេចបាន។




សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ភាគីហត្ថលេខី នៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស

ក្រោយពីមានការបែកបាក់ផ្ទៃក្នុង និង មានការញុះញង់ពីខាងក្រៅផងនោះ បេសកកម្ម និងដំណើរការរបស់គណបក្ស ត្រូវបានថមថយជាបន្តបន្ទាប់អស់រយៈពេលជាច្រើនឆ្នាំ ធ្វើឱ្យ ប្រជារាស្ត្រអ្នកគាំទ្រ អស់ទីពឹង និង ភាន់ច្រឡំ ។ ពេលនេះគណបក្សហ៊្វុនស៊ិនប៉ិច ក្រោម ការដឹកនាំរបស់ ព្រះអង្គម្ចាស់ នរោត្តម ចក្រាវុធ ព្រះបុត្រារបស់ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ បានរៀបចំកសាងកម្លាំងឡើងវិញ ។ ព្រះអង្គគឺជាមេដឹកនាំវ័យក្មេង ប្រកបដោយ សមត្ថភាព និង ថាមពលថ្មីក្នុងយុគ្គសម័យដឹកនាំដោយយុវជន និង digital ។



ព្រះអង្គម្ចាស់ នរោត្តម ចក្រាវុធ ព្រះប្រធានគណបក្ស ដឹកនាំបន្តវេន ពីព្រះបិតា និង ព្រះអយ្យកោ

ព្រះអង្គបានប្រកាន់គោលជំហរដឹកនាំយ៉ាងម៉ឺងម៉ាត់តាមព្រះរាជមាគ៌ាព្រះអយ្យកោ និង បទពិសោធន៍របស់ព្រះបិតា ប៉ុន្តែក្នុងយុទ្ធសាស្ត្រថ្មីដើម្បីនាំគណបក្សហ្វ៊ុនស៊ិនប៉ិច វិលទៅរកអតីតកាលដ៏រុងរឿង នាឆ្នាំ១៩៩៣ គឺការរួមសាមគ្គីគ្នាពីគ្រប់គណបក្សនយោបាយ ប្រជារាស្ត្រខ្មែរគ្រប់និន្នាការ ចូលរួមកសាងប្រទេស ដោយសុខសុវត្ថិភាពពេញបរិបូរណ៍។



សមាជិករដ្ឋសភា របស់គណបក្សហ្វ៊ុនស៊ិនប៉ិច អាណត្តិទី៧

ព្រះអង្គម្ចាស់ នរោត្តម ចក្រាវុធ ទ្រង់មានសង្ឃឹមថា នៅក្នុងឱកាសបោះឆ្នោត ជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤ នេះ អស់លោក លោកស្រី ជាសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ គ្រប់គណបក្ស រួមទាំងអតីតគណបក្ស នឹងចូលរួមគាំទ្រ គណបក្សហ្វ៊ុនស៊ិនប៉ិច ព្រោះមានតែ គណបក្សហ្វ៊ុនស៊ិនប៉ិច នេះទេ ដែលមានមូលដ្ឋានរឹងមាំ និង កក់ក្តៅសម្រាប់ អស់លោក លោកស្រី យើងទាំងអស់គ្នា បន្តសកម្មកសាងសង្គមជាតិ ពង្រឹងលទ្ធិប្រជាធិបតេយ្យ យុត្តិធម៌ និង នីតិរដ្ឋ ឱ្យប្រសើរឡើង ដូចដែលយើងធ្លាប់បានរួមសាមគ្គីគ្នាកាលឆ្នាំ១៩៩៣ ហើយ នឹងបន្តជាមួយគ្នាយូរអង្វែងតទៅអនាគត ៕

# រាស្ត្រធិបតេយ្យ សាសនា នីតិរដ្ឋ រាជបល្ល័ង្ក



ព្រះអង្គម្ចាស់ នរោត្តម ចក្រាវុធ ព្រះប្រធានគណបក្សហ្វ៊ុនស៊ិនប៉ិច មានជំនឿថា សមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ដែលជាអង្គបោះឆ្នោត នៃព្រឹទ្ធសភានីតិកាលទី៥ ឆ្នាំ២០២៤នេះ នឹងចូលរួមគាំទ្រគណបក្សហ្វ៊ុនស៊ិនប៉ិច ដើម្បីជាមូលដ្ឋានរឹងមាំ និង កក់ក្ដៅសម្រាប់យើងទាំងអស់គ្នា បន្តសកម្មកសាងសង្គមជាតិ ពង្រឹងលទ្ធិប្រជាធិបតេយ្យ យុត្តិធម៌ និង នីតិរដ្ឋឱ្យប្រសើរឡើង ដូចដែលយើងធ្លាប់បានរួមសាមគ្គីគ្នាកាលឆ្នាំ១៩៩៣ ។

# កម្មវិធី និងគោលនយោបាយសំខាន់ៗរបស់ គណបក្ស កម្លាំងជាតិ

នយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច គឺជាគោលការណ៍គ្រឹះសម្រាប់ការដឹកនាំ។ ការដឹកនាំនយោបាយ ដោយប្រកាន់យកគោលការណ៍សន្តិវិធី មិនញុះញង់ រួបរួមសាមគ្គី ឯកភាពជាតិ គោរពគ្នាទៅវិញទៅមកប្រកបដោយសីលធម៌ និងប្រកាន់ខ្ជាប់នូវសម្បជញ្ញជាតិ លើកទឹកចិត្តឱ្យប្រជាពលរដ្ឋចូលរួមដោះស្រាយបញ្ហាជាតិ ដើម្បីទទួលបាននូវសុខសន្តិភាព និងសុភមង្គលពិតប្រាកដ ទាំងផ្លូវកាយ ទាំងផ្លូវចិត្ត។

គណបក្ស កម្លាំងជាតិ មានគោលនយោបាយ និងកម្មវិធីនយោបាយសំខាន់ៗ ដូចខាងក្រោមៈ

## ១. នយោបាយ

គណបក្ស កម្លាំងជាតិ មានគោលនយោបាយ រួបរួមសាមគ្គីគ្នា ឯកភាពជាតិ ស្មោះត្រង់ចំពោះប្រជាពលរដ្ឋ និងប្រទេសជាតិ មិនរើសអើងគ្នា យោគយល់គ្នា អធ្យាស្រ័យគ្នា គោរពគ្នាទៅវិញទៅមក ដោយតម្កល់ផលប្រយោជន៍ប្រជាពលរដ្ឋ និងប្រទេសជាតិជាធំ។

### ១.១. នយោបាយក្នុងប្រទេស

- បំបាត់រាល់អំពើហិង្សាក្នុងសង្គម ធានាសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈពេញលេញជូនប្រជាពលរដ្ឋ និងធានាសន្តិភាពពិតប្រាកដ ជូនប្រទេសជាតិ។
- ការពារ និងលើកតម្កើងសិទ្ធិមនុស្ស អនុវត្តលទ្ធិប្រជាធិបតេយ្យសេរី ឱ្យបានត្រឹមត្រូវ និងពិតប្រាកដ។
- បំបាត់អំពើពុករលួយគ្រប់បែបយ៉ាង ពិសេសកែទម្រង់ប្រព័ន្ធយុត្តិធម៌ឡើងវិញ ដើម្បីធានាឱ្យមានភាពស្អាតស្អំ ផ្តល់យុត្តិធម៌ជូនជនរងគ្រោះពិតប្រាកដ។
- លើកតម្កើងយុត្តិធម៌សង្គម ជួយប្រជាពលរដ្ឋឱ្យមានជីវភាពធូរធារ ថ្លៃថ្នូរ និងផ្តល់លទ្ធភាព ស្មើគ្នាក្នុងការកសាងអនាគត។
- ធានាអព្យាក្រឹត្យភាពរដ្ឋបាលសាធារណៈ ឱ្យមានឯករាជ្យភាពពីគ្រប់គណបក្សនយោបាយ ដើម្បីបម្រើប្រជាពលរដ្ឋ ដោយមិនប្រកាន់បក្សពួក។
- កែទម្រង់ប្រព័ន្ធគ្រប់គ្រងដីធ្លីឡើងវិញ ការពារសិទ្ធិរបស់ប្រជាពលរដ្ឋ ប្រគល់សងជូនប្រជាពលរដ្ឋវិញនូវដីធ្លីទាំងឡាយ ដែលអ្នកមានអំណាច និងឈ្មួញទុច្ចរិតបានឃុបឃិតគ្នា ប្រព្រឹត្តអំពើពុករលួយរឹបអូសយកពីប្រជាពលរដ្ឋ ហើយផ្តល់ឱ្យកសិករគ្រប់រូបមានដីធ្លីស្រែចំការ និងមានទីជម្រកសមរម្យ។
- ការពារព្រំដែនប្រទេសកម្ពុជា ធានាបូរណភាពទឹកដីឱ្យបានគង់វង្ស។
- ដោះស្រាយបញ្ហាជនអន្តោប្រវេសន៍ដែលមករស់នៅដោយខុសច្បាប់។
- បញ្ឈប់ការកាប់ព្រៃឈើខុសច្បាប់ ការពាររាល់ទ្រព្យសម្បត្តិសាធារណៈ សម្បត្តិធម្មជាតិ និងសម្បត្តិវប្បធម៌របស់ប្រទេសជាតិ ឱ្យបានគង់វង្ស។
- ពិនិត្យឡើងវិញនូវកិច្ចសន្យាទាំងឡាយ ដែលមិនបម្រើឱ្យផលប្រយោជន៍ប្រជាពលរដ្ឋ និងប្រទេសជាតិ។

### ១.២. នយោបាយក្រៅប្រទេស

- កិច្ចការអន្តរជាតិ ដោយអនុវត្តតាមគោលការណ៍សន្តិសហវិជ្ជមានៈ
  - គោរពគ្នាទៅវិញទៅមក នូវបូរណភាពទឹកដី និងអធិបតេយ្យភាព។
  - មិនឈ្លានពានគ្នាទៅវិញទៅមក មិនគំរាមកំហែង មិនបង្កជម្លោះដោយយោធាជាមួយរដ្ឋហត្ថលេខីទាំងអស់។
  - ផ្តល់អត្ថប្រយោជន៍ទៅវិញទៅមកតាមរយៈការពង្រឹងទំនាក់ទំនងខាងសេដ្ឋកិច្ច-ពាណិជ្ជកម្ម និងវប្បធម៌ រវាងរដ្ឋ និងរដ្ឋ។
  - សន្តិសហវិជ្ជមាន ដោយគោរពគោលការណ៍ច្បាប់សំខាន់ៗ នៃទំនាក់ទំនងជាអន្តរជាតិ រវាងរដ្ឋ និងរដ្ឋ។
- ដោះស្រាយបញ្ហាព្រំដែន ដោយអនុលោមតាមរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាសន្ធិសញ្ញាសន្តិភាពទីក្រុងប៉ារីសឆ្នាំ១៩៩១ និងសន្ធិសញ្ញាស្របច្បាប់នានា។



ទិដ្ឋភាពអ្នកគាំទ្រ គណបក្ស កម្លាំងជាតិ

## ២. សេដ្ឋកិច្ច

ប្រកាន់យកគោលការណ៍សេដ្ឋកិច្ចទីផ្សារសេរី ដើម្បីសង្គម។ ការអភិវឌ្ឍដោយសមធម៌ លើកកម្ពស់ជីវភាពប្រជាពលរដ្ឋ បង្កើតការងារ និងបង្កើនប្រាក់ចំណូល។

### ២.១. វិស័យកសិកម្ម

- កែទម្រង់ដីធ្លី ដោយពិនិត្យឡើងវិញនូវរាល់កិច្ចសន្យាសម្បទានសេដ្ឋកិច្ចទាំងឡាយណា ដែលប៉ះពាល់ដល់ប្រយោជន៍ប្រទេសជាតិ និងប្រយោជន៍ប្រជាពលរដ្ឋ ដោយប្រែក្លាយសម្បទានសេដ្ឋកិច្ច ឱ្យទៅជាសម្បទានសង្គមកិច្ច ដើម្បីចែកជូនប្រជាពលរដ្ឋក្រីក្រ។
- ផ្តល់ប្លង់កម្មសិទ្ធិដីធ្លីជូនប្រជាពលរដ្ឋ ជាអាទិភាពផ្តល់ជូនកសិករ។
- ពង្រីកប្រព័ន្ធធារាសាស្ត្រខ្នាតតូច មធ្យម និងខ្នាតធំ ដើម្បីផ្គត់ផ្គង់តម្រូវការប្រជាពលរដ្ឋ។
- កំណត់តម្លៃប្រេងឥន្ទនៈ ជីកសិកម្ម សម្ភារកសិកម្ម និងថ្នាំសម្លាប់សត្វល្អិតជាដើម ឱ្យមានតម្លៃថោកប្រហាក់ប្រហែលនឹងប្រទេសជិតខាង។
- បំបាត់សិទ្ធិផ្តាច់មុខនៃការនាំចូល នាំចេញ ទិញ ឬលក់ ផលិតផល និងសម្ភារកសិកម្ម។

### ២.២. វិស័យឧស្សាហកម្ម និងសិប្បកម្ម

- ជានាអ្នកវិនិយោគដាក់ទុនក្នុងប្រទេស បង្កើតរោងចក្រ សហគ្រាស និងអាជីវកម្មនានា។
- បង្កើតមុខរបរសិប្បកម្ម ទៅតាមធនធានធម្មជាតិ ដែលមានតាមតំបន់ ដោយបង្កើតមណ្ឌលសិប្បកម្ម ដែលមានលក្ខណៈបច្ចេកទេស រកប្រភពដើមទុន និងទីផ្សារជូនសិប្បករ។

### ២.៣. វិស័យពាណិជ្ជកម្ម

- ធ្វើឱ្យមានតុល្យភាពជញ្ជីងពាណិជ្ជកម្ម រវាងប្រទេសជិតខាង និងក្នុងតំបន់។
- ស្មើភាពគ្នាក្នុងការប្រកួតប្រជែង ដោយឈរលើមូលដ្ឋានច្បាប់។
- បង្កលក្ខណៈងាយស្រួលដល់អ្នកវិនិយោគក្នុងប្រទេស និងក្រៅប្រទេស ឱ្យដាក់ទុនវិនិយោគ ដើម្បីបង្កើនចំណូលរដ្ឋ បង្កើតការងារ ជាប្រយោជន៍ប្រជាពលរដ្ឋ។
- បង្កើនផលិតផលក្នុងស្រុក ដើម្បីទប់ស្កាត់ការនាំចូល និងបង្កើនការនាំចេញ។

### ២.៤. វិស័យទេសចរណ៍

- ពង្រីកសេវាដឹកជញ្ជូនតាមផ្លូវគោក ផ្លូវទឹក និងផ្លូវអាកាស។
- គ្រប់គ្រងប្រាង្គប្រាសាទបុរាណ តំបន់ទេសចរណ៍នានា ដែលបុព្វបុរសបានបន្សល់ទុក។
- អភិវឌ្ឍន៍បន្ថែមលើវិស័យទេសចរណ៍ ពីការដឹកនាំជញ្ជូន និងរៀបចំសេវាស្នាក់នៅ ដោយថែរក្សាបេតិកភណ្ឌ និងបរិស្ថាន។

### ២.៥. វិស័យទូរគមនាគមន៍

- កំណែទម្រង់លើវិស័យទូរគមនាគមន៍។
- ប្រកួតប្រជែងតម្លៃដោយសេរី និងយុត្តិធម៌។

### ២.៦. ហិរញ្ញវត្ថុ

- លុបបំបាត់ការិយាធិបតេយ្យដ៏ស្មុគស្មាញ។
- ច្រកចេញ-ចូលតែមួយ។
- តម្រូវឱ្យចាយរូបិយវត្ថុជាតិផ្លូវការ គឺប្រាក់រៀល និងសហការពង្រីកការចាយប្រាក់រៀលទៅកាន់ទីផ្សារក្រៅប្រទេស។
- ទប់ស្កាត់ និងលុបបំបាត់អំពើលាងលុយកខ្វក់។

## ៣. សង្គមកិច្ច

គោលនយោបាយសង្គមកិច្ច គឺទប់ស្កាត់ និងលុបបំបាត់នូវល្បែងស៊ីសង ចោរកម្ម គ្រឿងញៀន គ្រឿងស្រវឹង ក្មេងទំនើង និងអំពើហិង្សា ដើម្បីផ្តល់ឱ្យប្រជាពលរដ្ឋទទួលបាននូវការរស់នៅក្នុងសង្គមមួយ ដែលមានសីលធម៌ខ្ពស់ សាសនាល្អ ត្រឹមត្រូវ យុត្តិធម៌ និងសុវត្ថិភាព។ លើសពីនេះទៅទៀត ផ្តល់ឱ្យប្រជាពលរដ្ឋទទួលបាននូវសេវារដ្ឋបាល សេវាសុខាភិបាល និងសេវាអប់រំ ប្រកបដោយក្រមសីលធម៌វិជ្ជាជីវៈ។

### ៣.១. សេវាសុខាភិបាល

- កំណែទម្រង់ប្រព័ន្ធសុខាភិបាល តាមរយៈការពន្យល់ អប់រំ ផ្សព្វផ្សាយឱ្យប្រជាពលរដ្ឋយល់ដឹងអំពីការថែរក្សាសុខភាព និងអនាម័យក្នុងការរស់នៅប្រចាំថ្ងៃ។
- ពង្រីកការប្រើប្រាស់ប្រព័ន្ធទឹកស្អាត ដែលជាកត្តាចម្បងក្នុងការថែរក្សាសុខភាព។
- ពង្រីកការប្រើប្រាស់បង្គន់អនាម័យ ដើម្បីជៀសវាងនូវការចម្លងមេរោគ។
- បង្កើនការផ្សព្វផ្សាយ និងអប់រំឱ្យយល់ដឹងអំពីបញ្ហាប្រឈមនៃការប្រើប្រាស់គ្រឿងញៀន។
- ពង្រីកមធ្យោបាយដឹកជញ្ជូន និងសង្គ្រោះបន្ទាន់សម្រាប់ដឹកអ្នកជំងឺ ដោយឥតគិតថ្លៃ។
- ពង្រីកឱ្យមានមណ្ឌលសុខភាពគ្រប់ឃុំ សង្កាត់ ដែលមានឧបករណ៍បរិក្ខាពេទ្យទំនើបទាន់សម័យ និង

ក្រុមគ្រូពេទ្យជំនាញ គោរពក្រមសីលធម៌វិជ្ជាជីវៈ ដើម្បីបម្រើប្រជាពលរដ្ឋ។

- ពង្រីកប្រព័ន្ធធានារ៉ាប់រងសុខភាព ដើម្បីឱ្យប្រជាពលរដ្ឋទទួលបានការពិនិត្យ ព្យាបាលជំងឺ នៅមន្ទីរពេទ្យរដ្ឋដោយឥតគិតថ្លៃ។

### ៣.២. សេវាអប់រំ វប្បធម៌ និងបរិស្ថាន

- កំណែទម្រង់ប្រព័ន្ធអប់រំស៊ីជម្រៅ និងបង្កើតឱ្យមានស្តង់ដាក្នុងការអប់រំ។
- ពង្រីកឱ្យមានសាលាមត្តេយ្យ នៅតាមភូមិ ឃុំ សង្កាត់ដែលមានតម្រូវការចំបាច់។
- ពង្រីកការអប់រំចំណេះទូទៅដែលមានបុគ្គលិកសិក្សាមានគរុកោសល្យច្បាស់លាស់។
- បណ្តាគ្រឹះស្ថានឧត្តមសិក្សា ទាំងសាធារណៈ និងឯកជន ត្រូវមាននិយាមគរុកោសល្យ និងបុគ្គលិកសិក្សាមានគរុកោសល្យច្បាស់លាស់។
- ផ្តល់អាហារូបករណ៍ដល់សិស្ស និស្សិតក្រីក្រដែលចង់បន្តការសិក្សានៅថ្នាក់ឧត្តមសិក្សា។
- ពង្រីកប្រព័ន្ធផ្តល់អាហារូបករណ៍ ជាប្រាក់កម្ចីដល់និស្សិតដោយយកការប្រាក់ទាបបំផុត។
- ពង្រីកមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈឱ្យមានជំនាញពិតប្រាកដ។
- ពង្រឹងប្រសិទ្ធភាពក្នុងការការពារបរិស្ថាន ធនធានធម្មជាតិ វប្បធម៌ និងបេតិកភណ្ឌជាតិ។

### ៣.៣. សេវារដ្ឋបាល

- កែទម្រង់រដ្ឋបាលសាធារណៈ។
- បំបាត់អំពើពុករលួយ និងឈ្មោះមន្ត្រីខ្មោច។
- ដាក់ពិន័យយ៉ាងតឹងរ៉ឹងចំពោះមន្ត្រីរាជការ ដែលអនុវត្តការងារផ្ទុយពីច្បាប់សហលក្ខន្តិកៈ មន្ត្រីរាជការ។
- ពង្រឹងសមត្ថភាព និងក្រមសីលធម៌មន្ត្រីមុខងារសាធារណៈ។
- ផ្តល់សេវាសាធារណៈផ្សេងៗ ជូនប្រជាពលរដ្ឋដោយឥតរើសអើង និងទាន់ពេលវេលា។

### ៣.៤. សន្តិសុខ សណ្តាប់ធ្នាប់

- ធានារក្សាសន្តិសុខ សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ តាមរយៈការពន្យល់ អប់រំ ផ្សព្វផ្សាយគោលការណ៍ច្បាប់ ដើម្បីកុំឱ្យមានក្មេងទំនើង និងអំពើហិង្សាក្នុងសង្គម។
- បំបាត់ល្បែងស៊ីសងខុសច្បាប់ ត្រួតពិនិត្យការផ្សព្វផ្សាយគ្រឿងស្រវឹង ដើម្បីទប់ស្កាត់អំពើពាលា និងហិង្សាក្នុងសង្គម។

### ៣.៥. ការងារ

- កំណែទម្រង់ប្រព័ន្ធគ្រប់គ្រងព័ត៌មានការងារ និងបង្កើតឱ្យមានស្តង់ដាមូលដ្ឋានសម្រាប់កន្លែងធ្វើការ។
- លើកទឹកចិត្តឱ្យបុគ្គលិកធ្វើការសិក្សា និងពង្រឹងសមត្ថភាពបន្ថែម។
- កំណត់ឱ្យមានប្រាក់បៀវត្សអប្បបរមារៀងរាល់ឆ្នាំ។
- ធានាឱ្យមានប្រាក់បំណាច់សមរម្យនិងសោធននិវត្តន៍។
- ពង្រឹង និងអនុវត្តច្បាប់ការងារ។

### ៣.៦. សាសនា

គណបក្ស កម្លាំងជាតិ មិនប្រកាន់ភេទ សាសនា ឬឋានៈ សង្គមឡើយ។ សាសនាមានតួនាទីយ៉ាងសំខាន់ក្នុងការចូលរួមអប់រំ និងលើកកម្ពស់សីលធម៌សង្គម បង្កើតនូវភាពសាមគ្គី យោគយល់ និងអធ្យាស្រ័យគ្នាទៅវិញទៅមក៕




*សកម្មភាពលើកស្លាក គណបក្ស កម្លាំងជាតិ*
*(នៅរាជធានី ភ្នំពេញ)*

សូមបោះឆ្នោតជូន គណបក្ស កម្លាំងជាតិ ដែលមានលេខរៀងទី៤

៤ ✓ គណបក្សកម្លាំងជាតិ គ.ក.ជ

# គណបក្ស ឆន្ទៈខ្មែរ

## KHMER WILL PARTY

សាមគ្គី គង់វង្ស ថ្កើងថ្កាន

លេខ ✓ គ.ឆ.ខ.

## គោលនយោបាយគណបក្ស ឆន្ទៈខ្មែរ

**គណបក្ស ឆន្ទៈខ្មែរ** នឹង ៖

១-រៀបចំឲ្យមានសន្តិភាពពិតប្រាកដ និងយូរអង្វែង។

២-ប្រកាន់គោលការណ៍អហិង្សា និងសន្តិវិធី ផ្អែកលើមូលដ្ឋាន**បង្រួបបង្រួមជាតិ ផ្សះផ្សាជាតិ** និង**ឯកភាពជាតិ** ដោយឈរលើ**ស្មារតីនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ថ្ងៃទី២៣ ខែតុលា ឆ្នាំ ១៩៩១។**

៣-ធានាការអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ ឲ្យបានត្រឹមត្រូវ។

៤-ប្រកាន់យកគោលការណ៍យុត្តិធម៌សង្គម ដោយរដ្ឋត្រូវធានាឲ្យប្រជាពលរដ្ឋទទួលបាននូវសិទ្ធិសេរីភាព ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ និងមានឱកាសស្មើគ្នាក្នុងវិស័យនយោបាយ សេដ្ឋកិច្ច និងសង្គមកិច្ច។

៥-ក្នុងនីតិកាលទី៥នេះ **គណបក្ស ឆន្ទៈខ្មែរ** នឹងយក**គោលនយោបាយសេដ្ឋកិច្ច**ជាអាទិភាព។

**<u>ការដោះស្រាយបញ្ហាសេដ្ឋកិច្ច ៖</u>**

**គណបក្ស ឆន្ទៈខ្មែរ** ប្រកាន់យកគោលការណ៍អភិវឌ្ឍន៍ប្រទេសប្រកបដោយនិរន្តរភាព ដែលជំរុញឲ្យមានការពង្រឹងការផលិតសម្រាប់នាំចេញ ប្រកបដោយភាពរឹងមាំ និងមានការប្រកួតប្រជែង។

**អង្គហេតុ និងបញ្ហាចម្បង**

- កម្ពុជាជាប្រទេសក្រីក្រក្នុងតំបន់អាស៊ានទន្ទឹមគ្នានឹងភូមា (មីយ៉ាន់ម៉ា)

-ក្នុងរយៈពេល ៣០ឆ្នាំចុងក្រោយនេះ សេដ្ឋកិច្ចកម្ពុជាមានកំណើនទាប បើប្រៀបធៀបនឹងប្រទេសជិតខាងក្នុងតំបន់។

**- ជាការពិត កម្ពុជាសព្វថ្ងៃ កំពុងជួបវិបត្តិសេដ្ឋកិច្ច ដូចជា ៖**

-បញ្ហាបំណុល

-បញ្ហាទីផ្សារការងារ

-បញ្ហាចំណូលប្រជាពលរដ្ឋទាប...។ល។

**- វិស័យកសិកម្ម**

- ប្រព័ន្ធធារាសាស្ត្រ ទន់ខ្សោយ (មានប្រឡាយ តែអត់ទឹក នៅរដូវប្រាំង)
- ទីផ្សារកសិផលមានទំហំតូច ភាគច្រើនពឹងផ្អែកលើប្រទេសជិតខាង ដែលនាំឱ្យកសិផលដែលលក់បានមានតម្លៃទាប និងគ្មានភាពនឹងនរ ដូចជាតម្លៃស្រូវ តម្លៃសាច់ជ្រូកជាដើម។

**- ផលិតកម្មឧស្សាហកម្ម**

**យើងស្ទើរតែគ្មានឧស្សាហកម្មកែច្នៃវត្ថុធាតុដើមកសិកម្ម** ហើយវិស័យនេះហើយដែលជាមូលដ្ឋានចម្បង សម្រាប់ផ្គត់ផ្គង់ការងារដល់ប្រជាពលរដ្ឋនៅតាមជនបទ និងជួយអោយរក្សាបាននូវស្ថិរភាពតម្លៃកសិផល។

**វិស័យវាយនភ័ណ្ឌ**ធ្លាក់ចុះ ហើយ**ដើម្បីឲ្យវិស័យនេះដំណើរការល្អឡើងវិញ** ទាល់តែកម្ពុជាទទួលបានមកវិញនូវប្រព័ន្ធអនុគ្រោះពន្ធអឺរ៉ុប(EBA) និងប្រព័ន្ធអនុគ្រោះពន្ធអាមេរិក(GSP)។ ដើម្បីទទួលបានប្រព័ន្ធអនុគ្រោះពន្ធនេះ ទាល់តែមានការពង្រឹងលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស។

**- វិស័យសំណង់ និងអចលនទ្រព្យ** ក៏មានការរាំងស្ទះដែរ ដោយសារចំណូលប្រជាជន មានការធ្លាក់ចុះ ហើយលំហូរសាច់ប្រាក់នៅតាមធនាគារ ក៏មានកម្រិតតិចតួច ។

សរុបមក **គ្រឹះសេដ្ឋកិច្ច**កម្ពុជា មានភាពទន់ខ្សោយ មិនអាចប្រកួតប្រជែងជាមួយប្រទេសនានា និងមិនអាចប្រឈមនឹងវិបត្តិសេដ្ឋកិច្ចសកល បានឡើយ។ ដូច្នេះហើយ បានជា**ប្រាក់ចំណូលរបស់ពលរដ្ឋកម្ពុជា** យើងនៅមានកំរិតទាប ហើយ**ទីផ្សារការងារកម្ពុជាយើង**តូចចង្អៀត មិនអាចផ្តល់ការងារគ្រប់គ្រាន់ដល់ពលរដ្ឋបានទេ ជាពិសេសយុវជនដែលចូលមកក្នុងទីផ្សារការងារប្រមាណ ៣សែននាក់បន្ថែមទៀត ជារៀងរាល់ឆ្នាំ។ ជាលទ្ធផល ពួកគេបង្ខំចិត្តធ្វើចំណាកស្រុកទៅប្រទេសថៃ ដើម្បីស្វែងរកការងារធ្វើ។

**ដូច្នេះតើ គណបក្ស ឆន្ទៈខ្មែរ ដែលបានទទួលបេសកកម្មពី គណបក្ស ភ្លើងទៀន ត្រូវដោះស្រាយបញ្ហាសេដ្ឋកិច្ចយ៉ាងដូចម្តេច?**

**១-កាត់បន្ថយថ្លៃដើមផលិតកម្មតាមរយៈ ៖**

- **បញ្ចុះតម្លៃអគ្គិសនី**ដល់កម្រិតប្រហាក់ប្រហែលប្រទេសជិតខាង; ពោលគឺ ៤០០ រៀល/គីឡូវ៉ាត់ សម្រាប់ប្រជាជនទូទៅ និង ១០០ រៀល/គីឡូវ៉ាត់ សម្រាប់អ្នកប្រើប្រាស់តិច។
- កាត់បន្ថយថ្លៃដឹកជញ្ជូន តាមរយៈ ៖
  - ការកែលម្អស្ថានភាពផ្លូវ និងស្ពាន
  - ការវិនិយោគលើប្រព័ន្ធផ្លូវដែក
  - ស្តារឡើងវិញនូវផ្លូវទឹក សម្រាប់ការដឹកជញ្ជូនដែលមានតម្លៃទាប។

**២-កម្ពុជាត្រូវពង្រីកលំហរសេរីភាពនយោបាយ និងពង្រឹងលទ្ធិប្រជាធិបតេយ្យ**អោយបានល្អឡើងវិញ ដើម្បីទទួលបានប្រព័ន្ធអនុគ្រោះពន្ធអឺរ៉ុប (EBA) និងប្រព័ន្ធអនុគ្រោះពន្ធអាមេរិក (GSP)។

**៣-ពង្រីក និងពង្រឹងនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ** ដើម្បីអោយមានការចូលរួមដ៏សកម្មពីសំណាក់ប្រជាជនមូលដ្ឋាន។

**៤-អន្តរាគមន៍សេដ្ឋកិច្ចដោយផ្ទាល់ក្នុងវិស័យកសិកម្ម ៖**

- មិនយកពន្ធ លើវិស័យកសិកម្ម និងឧស្សាហកម្មកែច្នៃ កសិកម្ម & ម្ហូបអាហារ
- វិនិយោគដោយមូលនិធិសាធារណៈ និងឧបត្ថម្ភធនធានមួយចំនួន សម្រាប់ឧស្សាហកម្មចំណីអាហារ និងកសិកម្មកែច្នៃ។

## គោលនយោបាយកិច្ចការបរទេស ៖

**ដើម្បីអោយការអនុវត្តនូវគោលនយោបាយក្នុងស្រុកខាងលើ ជាពិសេសគោលនយោបាយទាក់ទងទៅនឹងបញ្ហាសេដ្ឋកិច្ចនេះទទួលបានជោគជ័យ ៖**

- **នយោបាយការបរទេសរបស់កម្ពុជា ត្រូវតែប្រកាន់អោយបានខ្ជាប់ខ្ជួននូវ អព្យាក្រឹតភាព និងតុល្យភាពរវាងលោកខាងកើត និងលោកខាងលិច។**
- **សំខាន់បំផុត: កម្ពុជាត្រូវមាន ការបង្រួបបង្រួមជាតិ ការផ្សះផ្សាជាតិ និងឯកភាពជាតិស្របតាមស្មារតីនៃកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស ឆ្នាំ ១៩៩១។**

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
អគ្គលេខាធិការដ្ឋាន
លេខ: ០១៧ គ.ជ.ប.អគ្គ

### តារាងម៉ោងផ្សាយ
### កម្មវិធីផ្សព្វផ្សាយគោលនយោបាយរបស់គណបក្សនយោបាយ
### សម្រាប់ការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥ ឆ្នាំ២០២៤
### នៅទូរទស្សន៍ជាតិកម្ពុជា (ទទក) និងវិទ្យុជាតិកម្ពុជា

(ផ្សាយពីថ្ងៃទី១០ ខែកុម្ភៈ ដល់ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ២០២៤)

| ពេលវេលា | ទូរទស្សន៍ជាតិកម្ពុជា (ទទក) | វិទ្យុជាតិកម្ពុជា | | |
|---|---|---|---|---|
| | | AM 918KHz | FM 105.70MHz | FM 96MHz |
| ព្រឹក | ១០:០០-១២:៣០ នាទី | ៧:០០-៩:៣០ នាទី | ៧:០០-៩:៣០ នាទី | ៨:០០-១០:៣០ នាទី |
| រសៀល | ១៣:០០-១៥:៣០ នាទី | - | - | - |
| ល្ងាច | - | ១៦:២០-១៨:៥០ នាទី | ១៦:២០-១៨:៥០ នាទី | ១៦:០០-១៨:៣០ នាទី |

# គណបក្សនយោបាយដែលបានឈរឈ្មោះ បោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៥

គ.ជ.ប

(ថ្ងៃអាទិត្យ ទី២៥ ខែកុម្ភៈ ឆ្នាំ២០២៤)

| | |
|---|---|
| ១ | គណបក្សប្រជាជនកម្ពុជា<br>ប្រ.ជ |
| ២ | គណបក្ស ឆន្ទៈខ្មែរ<br>គ.ឆ.ខ |
| ៣ | គណបក្សហ្វ៊ុនស៊ិនប៉ិច<br>រ.រ.ជ.ភ.ឯ.អ.ស.ស |
| ៤ | គណបក្ស កម្លាំងជាតិ<br>គ.ក.ជ |

កំណត់សម្គាល់ ៖ នេះមិនមែនជាសន្លឹកឆ្នោតទេ